ក្លាយជាសមាជិក **RainWise** នៃប្រាក់សំណងមកវិញ សំរាប់សួនច្បារស្រូបទឹកភ្លៀង និងធុងស្តុកទឹកភ្លៀង

Seattle Public Utilities

King County

# ធុងស្តុកទឹកភ្លៀង ដំណោះស្រាយ RainWise ដ៏សំខាន់

គម្រោងដៃគូរវាងទីក្រុង Seattle និង King ខោនធី គឺកម្មវិធី **RainWise**, គឺជាកម្មវិធី ដែលផ្តល់ប្រាក់សំណង សំរាបសួនច្បារស្រូបទឹកភ្លៀង និងធុងស្តុកទឹកភ្លៀងនៅតាមទ្រព្យឯកជន ។ ប្រព័ន្ធទាំងនេះ ស្តុកទុកទឹកភ្លៀងដែលហូរធ្លាក់ពីដំបូលផ្ទះ ហើយស្តុកវាមិនឱ្យហូរចូលទៅបំពង់លូ ក្នុងអំឡុងពេលដែលមាន ព្យុះភ្លៀងធំ ។ មានម្ចាស់ទ្រព្យជាង 1600 នាក់ បានដំឡើងសួនច្បារស្រូបទឹកភ្លៀង និងធុងស្តុកទឹកភ្លៀង RainWise ហើយកំពុងជួយរក្សាផ្លូវទឹករបស់យើងឱ្យបានស្អាត ។

សួនច្បារស្រូបទឹកភ្លៀង អាចធ្វើឡើងបាននៅលើដីធ្លីដែលត្រូវតាមលក្ខខណ្ឌ ជាពិសេស ។ បើដីធ្លីនោះចោទខ្លាំងពេក តូចពេក ឬមានប្រព័ន្ធបង្ហូរ ទឹកភ្លៀងមិនគ្រប់គ្រាន់ សំរាប់ធ្វើសួនច្បារស្រូបទឹកភ្លៀងទេ អញ្ចឹងធុងស្តុកទឹកភ្លៀងអាចជាដំណោះស្រាយដ៏ល្អបំផុត ។



មិនមែនដីគ្រប់ទីកន្លែងទាំងអស់សុទ្ធតែសក្តិសមនឹងធ្វើសួនច្បារស្រូបទឹកភ្លៀងបាននោះទេ។ ធុងស្តុកទឹកភ្លៀងគឺជាដំណោះស្រាយដ៏ល្អបំផុត។





ធុងស្តុកទឹកភ្លៀងរាងទ្រវែង

## តើធុងស្តុកទឹកភ្លៀង RainWise គឺជាអ្វី?

ធុងស្តុកទឹកភ្លៀងគឺជាធុងធំមួយដាក់លើដី ដែលត្រូវបានប្រើដើម្បីត្រងទឹកភ្លៀងពីលើដំបូល ។ វាអាចផ្ទុកទឹកពី 200 ទៅជាង 1,000 កាឡុង ។ ធុងស្តុកទឹកភ្លៀងអាចមានរូបរាងខុសៗគ្នា រាប់ទាំងរាងមូល និងរាង "ទ្រវែង" ដែលមានទំហំប្រហែល 25 អ៊ីញ ។ ធុងស្តុកទឹកភ្លៀង ភាគច្រើនធ្វើពីជ័រប៉ូលីអេទីឡែនដែលធុនម៉ាំល្អ ហើយមានពណ៌ខុសៗគ្នា ប៉ុន្តែធុងនោះក៏អាចធ្វើពីដែកអ៊ីណុក និងវត្ថុធាតុផ្សេងទៀតផងដែរ ។

ធុងស្តុកទឹកភ្លៀងត្រូវបានគេប្រើប្រាស់នៅជុំវិញពិភពលោកដើម្បីត្រងទឹកភ្លៀង ប៉ុន្តែធុងទឹក RainWise ក៏ជួយកាត់បន្ថយបរិមាណទឹកហូរចូលលូកុំឱ្យវាជន់លូផងដែរ ។ ធុងនោះត្រូវបានបំពាក់ដោយសន្ទះវ៉ាល់បិទ-បើក ដើម្បីឱ្យទឹកក្នុងធុងអាចហូរចូលទៅប្រព័ន្ធលូបានយឺត ។ សន្ទះវ៉ាល់នេះ ត្រូវបានគេបើកនៅដើមរដូវវស្សា ដើម្បីបង្ហូរទឹកក្នុងធុងចេញឱ្យអស់បន្ទាប់ពីព្យុះភ្លៀងម្តងៗ ហើយត្រៀមរួចជាស្រេចដើម្បីត្រងបំពេញយកទឹកភ្លៀងថ្មី ។ នៅប្រហែលនៅខែឧសភា សន្ទះវ៉ាល់បិទបើកនោះអាចត្រូវបានគេបិទ ដើម្បីរក្សាស្តុកទុក និងប្រើទឹកភ្លៀងសម្រាប់រដូវក្តៅ ។

# ខ្ញុំចង់ដាក់ធុងស្តុកទឹកភ្លៀងមួយ ឬច្រើន ។ **តើត្រូវធ្វើអ្វីទៅបន្ទាប់មកទៀត?**

1. **សូមពិនិត្យមើលថាតើអ្នកមានសិទ្ធិទទួលបានដែរឬទេ** នៅឯ **_www.700milliongallons.org/rainwise/eligibility-map/_** វាយអាស័យដ្ឋានរបស់អ្នក ដើម្បីឱ្យដឹងថាតើអ្នកមានសិទ្ធិទទួលបានប្រាក់សំណងមកវិញដែរឬទេ និងថាតើមធ្យោបាយប្រភេទមួយណាដែលអ្នកមានសិទ្ធិទទួលបាន (សួនច្បារស្រូបទឹកភ្លៀង និង/ឬធុងស្តុកទឹកភ្លៀង) ។

2. **ចូរជ្រើសរើសជាងម៉ៅការរបស់អ្នក** ដោយចុចលើអក្សរ " Find Contractors " នៅលើគេហទំព័រ ឬចូលរួមក្នុងពិធីជួបជាងម៉ៅការ ។

3. **ជាងម៉ៅការរបស់អ្នកនឹងជួយអ្នកឆ្លើយនូវសំណួរដូចខាងក្រោម** សម្រាប់ទីតាំងដីរបស់អ្នក:
   - ផ្ទៃដំបូលដែលអ្នកអាចត្រងទឹកភ្លៀងបាន
   - ជម្រើសធុង និងទីតាំងដាក់ធុងស្តុកទឹកភ្លៀង
   - ប្រភេទធុង និងថ្ងៃខែដំឡើង
   - តម្លៃសរុប ចំនួនទឹកប្រាក់សំណង និងរបៀបទទួលបានប្រាក់សំណង ។

4. ប្រសិនបើអ្នកសំរេចចិត្តដាក់ធុងស្តុកទឹកភ្លៀងនោះ ជាងម៉ៅការរបស់អ្នក **នឹងកំណត់ថ្ងៃខែទៅពិនិត្យទីតាំងជាមុន ហើយធ្វើការតំឡើង។**

5. **បន្ទាប់ពីការសាងសង់បានចប់រួចរាល់ ជាងម៉ៅការរបស់អ្នកនឹងណាត់ពេលធ្វើការពិនិត្យចុងក្រោយ។** អ្នកត្រួតពិនិត្យ RainWise នឹងធ្វើការបញ្ជាក់ថា ការដំឡើងប្រព័ន្ធរបស់អ្នកត្រូវបានធ្វើឡើងត្រឹមត្រូវដែរឬទេ ។

6. **ទទួលយកប្រាក់សំណងរបស់អ្នក!** សូមដាក់ពាក្យសុំប្រាក់សំណងរបស់អ្នក ហើយទទួលបានប្រាក់សំណងរបស់អ្នកក្នុងរយៈពេលពី ៦ ទៅ ៨ សប្តាហ៍ ។

7. **ចូលថែទាំធុងស្តុកទឹកភ្លៀងរបស់អ្នក** យ៉ាងហោចណាស់ឱ្យបានរយៈពេលប្រាំឆ្នាំ ។ ជាងម៉ៅការរបស់អ្នកនឹងប្រាប់អ្នកអំពីរបៀបថែទាំយ៉ាងងាយស្រួល ។



**ធុងស្តុកទឹកអាចជាធុងមួយ ឬធុងច្រើនតភ្ជាប់គ្នា**

## គម្រោងធុងស្តុកទឹកភ្លៀងជាធម្មតារួមមាន

- ធុងស្តុកទឹកភ្លៀង និងទុយោទឹកសំរាប់ភ្ជាប់ រួមទាំងសន្ទះវ៉ាល់បិទ-បើកឱ្យទឹកហូរយឺត
- គ្រឹះសុវត្ថិភាព (គ្រឹះបេតុង ឬចាក់ស្រទាប់ខ្សាច់ គ្រោះ ចាក់កៅស៊ូ)
- អាចផ្លាស់ប្តូរទត្រងទឹក និងបំពង់បង្ហូរទឹក ដើម្បីឱ្យទឹកភ្លៀងហូរចូលក្នុងធុងស្តុកទឹកភ្លៀងនោះ
- តំឡើងតភ្ជាប់ប្រព័ន្ធការពារកុំឱ្យទឹកហៀរ ដូច្នេះពេលធុងទឹកនោះពេញក្នុងអំឡុងពេលព្យុះភ្លៀងធំ វាអាចហៀរទៅប្រព័ន្ធលូទឹក ឬសួនច្បារស្រូបទឹកភ្លៀងបានដោយគ្មានបញ្ហា ។






**អាគារធំ មួយចំនួនដែលបានធ្វើការដំឡើង _RainWise_ រួចហើយ។ វិហារជំនុំ _Alnoor Mosque congregation_ (រូបខាងលើ) បានជ្រើសរើសយកជម្រើសធុងទ្រវែង ដើម្បីឱ្យសម ទៅតាមទំហំដីតូចចង្អៀត។ នៅវិហារ _United Methodist Church_ (រូបខាងឆ្វេង) ធុងស្តុកទឹកភ្លៀងធំចំនួន ៣ ដែលធុងទាំងនោះត្រងទឹកភ្លៀងបានទាំងអស់ពីដំបូលវិហារ ហើយយកទឹកនោះប្រើស្រោចសួនរបស់ខ្លួននៅរដូវក្តៅ។**

# RainWise នឹងជួយចេញថ្លៃសម្រាប់ដាក់ធុងស្តុក-ទឹកភ្លៀង!

**ប្រាក់សំណងជាមធ្យមពី RainWise គឺចំនួន $4,800**

ប្រាក់សំណងពី RainWise សម្រាប់ដាក់ធុងស្តុកទឹកភ្លៀងគឺមានចំនួនខុសគ្នាទៅតាមទំហំហ្វូតការ៉េនៃផ្ទៃដំបូលដែលអាចត្រងទឹកភ្លៀងបាន និងទំហំធុងស្តុកទឹកភ្លៀង (ដែលមានចន្លោះពី $3.09 ទៅ $4.00 ដុល្លារ ក្នុងមួយហ្វូតការ៉េ) ។ ប្រាក់សំណងធុងស្តុកទឹកភ្លៀងជាធម្មតាចេញឱ្យចន្លោះពី 50 ទៅ 100 ភាគរយ នៃថ្លៃចំណាយសរុប ។ ទាល់តែមានផ្ទៃដំបូលដែលអាចត្រងទឹកភ្លៀងបានយ៉ាងហោចណាស់ 400 ហ្វីតការ៉េ ទើបមានសិទ្ធិទទួលបានប្រាក់សំណង ។ ការដំឡើងអាចជាធុងស្តុកទឹកមួយ ធុងស្តុកទឹកជាច្រើនដែលតភ្ជាប់គ្នានៅក្នុងទីតាំងមួយ ឬធុងស្តុកទឹកជាច្រើននៅក្នុងទីតាំងផ្សេង ។





**ធុងស្តុកទឹកភ្លៀងអាចមានរាង ទំហំ និងពណ៌ផ្សេងគ្នា ដើម្បីឱ្យសមទៅនឹងទីតាំងដីរបស់អ្នក។**

រូបថតដែលបានផ្តល់ជូន ដោយក្រុមហ៊ុន Rain Dog



## ធុងស្តុកទឹកមានភាពងាយស្រួលក្នុងការថែទាំ

ការថែទាំធុងស្តុកទឹកគឺមានភាពងាយស្រួលយ៉ាងខ្លាំង ។ សំណាញ់នៅខាងក្នុងធុងស្តុកទឹកជួយទប់សំរាមធំៗ ដូចជាស្លឹកជាដើម ។ នៅរដូវស្លឹកឈើជ្រុះ វាចាំបាច់ត្រូវសម្អាតសំណាញ់នោះ ហើយបង្ហូរចោលនូវដីដែលអាចមាននៅបាតធុង ។ វាក៏ជាការសំខាន់ផងដែរ ត្រូវចៀសវាងការកកស្ទះធុងស្តុកទឹក ដោយធ្វើការលាងសំអាតស្លឹកឈើជ្រុះ និងសំរាមនៅតាមទរទឹករបស់អ្នក ។

សន្ទះវ៉ាល់បិទ-បើកទឹកហូរឃឹត ត្រូវតែបើកនៅខែកញ្ញា ដើម្បបញ្ចេញទឹកឃឹតក្នុងកំឡុងពេញរដូវវស្សា ។ សន្ទះនេះអាចត្រូវបានគេបិទជាថ្មីម្តងទៀតនៅចុងរដូវផ្ការីក ដើម្បីទប់ទឹកភ្លៀង សម្រាប់ប្រើប្រាស់នៅរដូវក្តៅ ។

ការណែនាំពីវិធីថែទាំត្រូវបានផ្តល់ជូននៅពេលគេដំឡើងធុងទឹកនីមួយៗ ហើយជាងម៉ៅការតំឡើងធុង RainWise របស់អ្នកនឹងបង្ហាញពីរបៀបថែទាំវា ។ សម្រាប់ព័តិមានបន្ថែម សូមចូលទៅ *www.700milliongallons.org/rainwise/maintenance/.*

# បន្ថែម

ប្រាក់សំណង RainWise ចេញថ្លៃឱ្យស្មើរតែទាំងស្រុង (ប្រសិនបើមិនបានចេញឱ្យទាំងអស់) នៃការចំណាយលើការដំឡើងធុងស្តុកទឹក ។ មានអតិថិជនមួយចំនួនក៏បានជ្រើសរើសឧបករណ៍ដាក់បន្ថែមទៀត ដែលមិនត្រូវបានគេផ្តល់នូវប្រាក់សំណងពី RainWise នោះទេ ។


រូបថតដែលបានផ្តល់ជូន របស់ក្រុមហ៊ុន Rain Dog

អតិថិជនមួយចំនួនមានចំណាប់អារម្មណ៍លើម៉ាស៊ីនបូមទឹក ដើម្បីជួយក្នុងការបូមទឹកយកមកប្រើនៅរដូវក្តៅ។

**ម៉ាស៊ីនបូមទឹក** មានអតិថិជនដែលដាក់ធុងស្តុកទឹកជាច្រើននាក់ មានចំណាប់អារម្មណ៍ក្នុងការបំពាក់ម៉ាស៊ីនបូមទឹក ដើម្បីយកទឹកភ្លៀងប្រើនៅរដូវក្តៅឱ្យកាន់តែងាយស្រួល ។ មានជម្រើសជាច្រើនដែលអាចរកបាន (រួមបញ្ចូលទាំងម៉ាស៊ីនបូមទឹកប្រើថាមពលព្រះអាទិត្យ) ។ ចូរពិភាក្សាជាមួយជាងម៉ៅការរបស់អ្នកអំពីព័ត៌មានលម្អិត ។

## ជម្រើសលើសោភណ្ឌភាព — គំនូរ ផ្ទាំងបាំង ឬរបងហ៊ុមព័ទ្ធ:

មានវិធីជាច្រើនក្នុងការតំឡើងធុងស្តុកទឹកភ្លៀងនៅលើដីរបស់អ្នក អាស្រ័យទៅតាមចំណង់ចំណូលចិត្តផ្នែកសោភ័ណ្ឌភាពរបស់អ្នក ។ អតិថិជនមួយចំនួនដាក់សំណាញ់រុំ ដាំដើមឈើលំអ ឬដាក់វានៅជាប់នឹងជញ្ជាំងតាមបណ្តោយផ្លូវដើរ ដើម្បីបិតបាំងធុងទឹករបស់ខ្លួន ។ ធ្វើរបង ឬដាក់សំណាញ់អាចទទួលបាននូវប្រាក់សំណង ប៉ុន្តែជាធម្មតាមិនត្រូវបានគេសងឱ្យទាំងអស់នោះទេ ត្រូវមានការចំណាយចេញដោយខ្លួនឯងខ្លះ។ ចូរពិភាក្សាជាមួយជាងម៉ៅការរបស់អ្នក អំពីជម្រើសដែលអ្នកចង់បាន ។


រូបថតដែលបានផ្តល់ជូន របស់ក្រុមហ៊ុន Rain Dog






**មានសំណួរអ្វីទេ?**
**ត្រូវការព័ត៌មានបន្ថែម?**

សូមចូលមើលលើគេហទំព័រ ***www.rainwise.seattle.gov***.
ផ្ញើអ៊ីម៉ែលមកយើងខ្ញុំតាមរយៈ **rainwise@seattle.gov**
ឬទូរស័ព្ទទៅបណ្តាញផ្នែកបំរើខាងសួនច្បារ តាមរយៈលេខ
**206-633-0224**

មានទម្រង់ផ្សេងទៀតដែលអាចរកបាន ។
206-633-0224 ទូរស័ព្ទបញ្ជូនបន្ត
TTY តាមលេខ 711

Seattle Public Utilities    King County

1612_7010w_cistern_factsheet_CA.ai